# ការរំលាយកិច្ចសន្យា

ឧទ្ទេសនាមដោយ
លោកមេធាវី អ៊ីច ប៉ូលី

07/12/2017

# ការរំលាយកិច្ចសន្យា




ក្រ.រដ្ឋប្បវេណី

- បទបញ្ញត្តិទូទៅ (គន្ថីទ១)
- បុគ្គល (គន្ថីទ២)
- សិទ្ធិប្រត្យក្ស (គន្ថីទ៣)
- កាតព្វកិច្ច (គន្ថីទ៤)
- កិច្ចសន្យាសំខាន់ៗ (គន្ថីទ៥)
- ការធានាកាតព្វកិច្ច (គន្ថីទ៦)
- ញាតិ (គន្ថីទ៧)
- សន្តតិកម្ម (គន្ថីទ៨)
- អវសានប្បញ្ញត្តិ (គន្ថីទ៩)

# មាតិកា

- មូលហេតុនៃការសង្គ្រោះកិច្ចសន្យា
  - ក ការអនុវត្តកាតព្វកិច្ចមិនពេញលេញ
  - ខ ការអនុវត្តកាតព្វកិច្ចយឺតយ៉ាវ
  - គ អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច
  - ឃ ករណីផ្សេងៗទៀតដែលគ្មានការអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច

# មាតិកា

II វិធីនៃការសម្រួលកិច្ចសន្យា

ក ការអនុវត្តដោយបង្ខំ

ខ ការទាមទារសំណងនៃការខូចខាត

គ ការរំលាយកិច្ចសន្យា

III អានុភាពនៃការរំលាយកិច្ចសន្យា

ក ការរួចផុតពីកាតព្វកិច្ច

ខ កាតព្វកិច្ចបដិទាន

គ ការសងការប្រាក់

# I មូលហេតុនៃការសង្គ្រោះកិច្ចសន្យា

កិច្ចសន្យាត្រូវបានសង្គ្រោះនៅពេលភាគីនៃកិច្ចសន្យារងនូវការបំពានពីភាគីម្ខាងទៀតនៃកិច្ចសន្យា តាមរយៈការមិនអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យា។ ទម្រង់នៃការមិនអនុវត្តកាតព្វកិច្ចមានដូចជា(CC#389) ៖

ទី១ ការអនុវត្តកាតព្វកិច្ចមិនពេញលេញ

ទី២ ការអនុវត្តកាតព្វកិច្ចយឺតយ៉ាវ

ទី៣ អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច

ទី៤ ករណីផ្សេងទៀតដែលគ្មានការអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យា

# I មូលហេតុនៃការសទ្រ្គោះកិច្ចសន្យា

## ក. ការអនុវត្តកាតព្វកិច្ចមិនពេញលេញ

ខ្ញុំខ្ចីលុយ
10000$សងនៅ
ថ្ងៃ20/8/2015



A

យល់ព្រម



B

**ដល់ថ្ងៃ20/8/2015 A សង
បានតែ5000$នេះហៅថាថា
ការអនុវត្តកាតព្វកិច្ចមិនពេញលេញ**

# | មូលហេតុនៃការសម្រេចសន្យា

## ខ ការអនុវត្តកាតព្វកិច្ចយឺតយ៉ាវ

ប្រសិនបើ មានពេលវេលាពិតប្រាកដក្នុងការអនុវត្តកាតព្វកិច្ច កូនបំណុលត្រូវទទួលខុសត្រូវចំពោះការយឺតយ៉ាវនោះ ប្រសិនបើពេលវេលាមិនពិតប្រាកដ កូនបំណុលត្រូវទទួលខុសត្រូវនៅពេល ដឹងអំពីការមកដល់ និងប្រសិនបើមិនកំណត់អំពីពេលវេលាអនុវត្តកាតព្វកិច្ច កូនបំណុលនោះត្រូវទទួលខុសត្រូវ ចំពោះការយឺតយ៉ាវ ក្រោយពេលដែលកូនបំណុលនោះបានទទួលការទាមទារឱ្យអនុវត្តCC#391។

# | មូលហេតុនៃការសទ្ត្រាះកិច្ចសន្យា

ខ្ញុំសុំខ្ចីលុយ
សន្យាសងនៅ
ថ្ងៃ20/8/2015

យល់ព្រម




A

ដល់ថ្ងៃ27/8/2015
ទើបA សង នេះហៅថា
ការអនុវត្តកាតព្វកិច្ចយឺតយ៉ាវ



B

# I មូលហេតុនៃការសង្គ្រោះកិច្ចសន្យា

## គ អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច CC#392

A និង B បានចុះកិច្ចសន្យាទិញលក់ដីក្នុងតម្លៃ100.000$ដោយBបានកក់ 50.000$។ B សន្យាថានៅពេលA ផ្ទេរកម្មសិទ្ធិ B បង់បង្គ្រប់ឱ្យ A



Aអ្នកលក់

តែមុនកាលបរិច្ឆេទប្រគល់ដី ដីលេចចូលទន្លេបាត់



នេះហៅថា អលទ្ធភាពក្នុងការអនុវត្តកាតព្វកិច្ច



Bអ្នកទិញ

# មូលហេតុនៃការសគ្រោះកច្ចសន្យា

## ឃ ករណីផ្សេងៗទៀតដែលគ្មានការអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ច CC#394






បើកម្មកររោងចក្រកំពុងធ្វើការងារបានជួបគ្រោះថ្នាក់ដោយខ្វះឧបករណ៍សុវត្ថិភាពគ្រប់គ្រាន់ ដូចនេះពួកគេអាចទាមទារឱ្យរោងចក្រទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួនបាន។

# | មូលហេតុនៃការសព្ត្រោះកច្ចសន្យា



B បានទិញសត្វពី A ដោយបានលក់សត្វដែលឈឺឱ្យមកB ទើបធ្វើឱ្យឆ្លងដល់សត្វរបស់Bផ្សេងទៀត



A អ្នកលក់

B អ្នកទិញ





# II វិធីនៃការសង្គ្រោះកិច្ចសន្យា

វិធីនៃការសង្គ្រោះកិច្ចសន្យាមាន ៣ គឺ

ទី១ការអនុវត្តកាតព្វកិច្ចដោយបង្ខំ

ទី២សំណងនៃការខូចខាត និង

ទី៣ ការរំលាយកិច្ចសន្យា CC#390។

ម្ចាស់បំណុលអាចប្រើមធ្យោបាយនេះ លើសពីមួយបាន កុំឱ្យតែធម្មជាតិនៃមធ្យោបាយនោះមានលក្ខណៈផ្ទុយគ្នា។

# II វិធីនៃការសម្រួះកិច្ចសន្យា

## ក ការអនុវត្តដោយបង្ខំ

ជាវិធានចាប់បង្ខំឱ្យកូនបំណុលអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយបង្ខំតាមវិធានតុលាការ ប៉ុន្តែប្រសិនបើលក្ខណៈសារធាតុនៃកាតព្វកិច្ច មិនអាចអនុវត្តកាតព្វកិច្ចដោយបង្ខំម្ចាស់បំណុលមិនគប្បីប្រើវិធាននេះឡើយ(CC#396)។

# II វិធីនៃការសង្គ្រោះកិច្ចសន្យា

A និង B បានចុះកិច្ចសន្យាថតភាពយន្តមួយចប់ ដោយ B ទទួលបាន30000$ ហើយសន្យាថា នឹងថតឱ្យចប់ដោយមិនឈប់ តែថតបា 2 ខែ ក៏លែងថត។

ករណីនេះ A មិនអាចប្រើ
វិធានអនុវត្តដោយបង្ខំទេ



A អ្នកតំណាង
ក្រុមហ៊ុន
ភាពយន្ត



B តារាង
សំដែង

# II វិធីនៃការសង្គ្រោះកិច្ចសន្យា



A និង B បានចុះកិច្ចសន្យាជួលដីក្នុងតម្លៃ1000$/ខែ សម្រាប់រយៈពេល 5 ឆ្នាំ ដោយអាចសាងសង់អាគារលើដីនោះបាន។ ដល់កាលកំណត់ B អត់បានបន្តកិច្ចសន្យាជួលថ្មី A ក៏ឱ្យ B រុះរើសំណង់នោះតែ B មិនព្រម។



A ភតិបតី

B ភតិក




ក្នុងករណីនេះ A អាចអនុវត្តបង្ខំដោយផ្ទាល់ចំពោះ B ឬ ស្នើសុំអនុវត្តបង្ខំតាមវិធានជំនួសបើ B មិនព្រម។

# II វិធីនៃការសម្រេចកិច្ចសន្យា

## ខ ការទាមទារសំណងនៃការខូចខាត

ជាការខូចខាតដែលកើតឡើង មកពីការមិនអនុវត្តកាតព្វកិច្ចតាមខ្លឹមសារនៃកិច្ចសន្យារបស់កូនបំណុល ដែលការមិនអនុវត្តកាតព្វកិច្ចនោះ បណ្តាលឱ្យមានការខូចខាតចំពោះម្ចាស់បំណុលCC#398។

# II វិធីនៃការសង្គ្រោះកិច្ចសន្យា

- **សំណងនៃការខូចខាតធម្មតា** CC#401 ក

A និង B បានបង្កើតកិច្ចសន្យាជួលផ្ទះដោយ Aត្រូវប្រគល់ផ្ទះឱ្យ B លុះដល់កំណត់ត្រូវប្រគល់ផ្ទះAមិនប្រគល់ឱ្យ B ទើបធ្វើ ឱ្យ B ជួលសណ្ឋាគារដើម្បីស្នាក់ ដោយនៅក្នុង 1 ថ្ងៃ 50$។ ដូចនេះ សោហ៊ុយចំណាយក្នុង 1 ថ្ងៃ 50$ គឺជាការខូចខាតធម្មតា។



A ភតិបតី






B ភតិក

# II វិធីនៃការសម្រាះកិច្ចសន្យា

➤ **សំណងនៃការខូចខាតពិសេស**

សំណងនៃការខូចខាតពិសេស គឺជាសំណងនៃការខូចខាតដែលកើតឡើងដោយសារកាលៈទេសៈពិសេស ហើយគូភាគីអាចព្យាករណ៍បាន ហេតុនេះ សំណងនៃការខូចខាតពិសេសមិនត្រូវបានទទួលស្គាល់ឡើយ ក្នុងករណីភាគីមិនអាចព្យាករណ៍បានCC#401។

# II វិធីនៃការសង្គ្រោះកិច្ចសន្យា



A បានយកឡានទៅផ្ញើនៅចំណត B បើឡានបាត់ដោយកំហុសB នោះAអាចទាមទារការខូចខាតធម្មតាពីBបាន។ តែចៃដន្យក្នុងនោះមានកងដៃពេជ្រការបាត់បង់នេះ ជាការខូចខាតពិសេស។ ហេតុនេះបើ B បានដឹងថាមានកងដៃពេជ្រនោះ A អាចទាមទារសំណងនៃការខូចខាតពិសេសនេះបាន បើបានព្រមព្រៀងគ្នា។







A

B



# II វិធីនៃការសម្រួលកិច្ចសន្យា

➢ **លក្ខខណ្ឌនៃសំណង**

លក្ខខណ្ឌដើម្បីទាមទារសំណងនៃការខូចខាត (CC#398) ៖

(១) ការមិនអនុវត្តកាតព្វកិច្ចរបស់កូនបំណុល

(២)អត្ថិភាពនៃការខូចខាត

(៣) កំហុសរបស់កូនបំណុល

(៤) ទំនាក់ទំនងហេតុផល

ប៉ុន្តែក្នុងករណីមានការកំណត់ជាមុននូវសំណងនៃការខូចខាត លក្ខខណ្ឌក្នុងការទាមទារ សំណងអនុលោមតាមខសន្យានោះ ប្រសិនបើ ខសន្យានោះមានសុពលភាព។

# II វិធីនៃការសម្រួលកិច្ចសន្យា

- គ. ការរំលាយកិច្ចសន្យា

ភាគីនៃកិច្ចសន្យាអាចរំលាយកិច្ចសន្យាបាន បើបានបំពេញតាមលក្ខខណ្ឌច្បាប់ ឬព្រមព្រៀងគ្នា ជាអាទិ៍។ ការរំលាយកិច្ចសន្យា អាចធ្វើឡើងតាមរូបភាព ០៣ (បី) យ៉ាង

ទី១ ការរំលាយកិច្ចសន្យាតាមច្បាប់

ទិ២ ការរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា និង

ទី៣ ការរំលាយកិច្ចសន្យាតាមការព្រមព្រៀង។

# II វិធីនៃការសម្រោះកិច្ចសន្យា

**ការរំលាយកិច្ចសន្យាតាមច្បាប់** តម្រូវឲ្យបំពេញលក្ខខណ្ឌ២(ពីរ)

ទី១ កិច្ចសន្យានោះជាកិច្ចសន្យាអញ្ញមញ្ញ និង

ទី២ ភាគីម្ខាងទៀតបានបំពានកិច្ចសន្យានោះធ្ងន់ធ្ងរ (CC#407)។

បំពានកិច្ចសន្យាធ្ងន់ធ្ងរគឺជាស្ថានភាព (CC#408)

ក. បានដាស់តឿន និងកំណត់អំឡុងពេលសមរម្យសម្រាប់អនុវត្ត ប៉ុន្តែអំឡុងពេលនោះបានកន្លងផុត នៅតែមិនអនុវត្តកាតព្វកិច្ច ឬ

ខ.ភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់ក្នុងកិច្ចសន្យា ឬ

គ.ភាគីមិនអាចអនុវត្តតាមកាលិកចម្បង ឬ

ឃ.ភាគីបំពានកិច្ចសន្យាហួសហេតុ ធ្វើឲ្យបាត់ទំនុកចិត្ត។

# II វិធីនៃការរំលោភកិច្ចសន្យា

- **ការដាស់តឿន៖**

ភាគីម្ខាងបានដាស់តឿនភាគីម្ខាងទៀត ដែលមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ ដោយបានកំណត់អំឡុងពេលសមរម្យដើម្បីអនុវត្តកាតព្វកិច្ចហើយ ប៉ុន្តែកាតព្វកិច្ចមិនត្រូវបានអនុវត្តនៅក្នុងអំឡុងពេលនោះ។

# II វិធីនៃការសង្គ្រោះកច្ចសន្យា

ខ្ញុំសុំខ្ចីលុយលោក 10000$ផង!

អ្នកស្រីសុំ សងលុយខ្ញុំក្នុង អំឡុងពេល 1 សប្តាហ៍



កិច្ចសន្យាខ្ចីបរិភោគ
កំណត់សងនៅថ្ងៃទី២០ ខែ សីហា ឆ្នាំ ២០១៥

ថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៥
ពេលកំណត់សង បានមកដល់



A

B

អំឡុងពេលមួយសប្តាហ៍បានមកដល់A នៅតែមិន បានសងប្រាក់ទៅB។
(ករណីនេះហៅថា មានការបំពានកិច្ចសន្យាធ្ងន់ធ្ងរ)

# II វិធីនៃការសម្រោះកិច្ចសន្យា

- ភាគីមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់នៅក្នុងកិច្ចសន្យា

ថ្ងៃទី២០ ខែ សីហា ឆ្នាំ២០១៦
មកដល់ នំខួបអាពាហ៍ពិពាហ៍
មិនទាន់ធ្វើហើយ



A

កិច្ចសន្យាលក់ ទិញ នំខួប
អាពាហ៍ពិពាហ៍
ថ្ងៃទី២០ ខែ សីហា ឆ្នាំ
២០១៦





B

**ភាគីមិនអនុវត្តកាតព្វកិច្ចតាមពេលកំណត់នៅក្នុងកិច្ចសន្យា៖**
ករណីគោលបំណងនៃកិច្ចសន្យាមិនបានសំរេចសោះ បើភាគីមិនបានអនុវត្តតាមពេលកំណត់។
ករណីនេះហៅថា មានការបំពានកិច្ចសន្យាធ្ងន់ធ្ងរ។

# II វិធីនៃការសង្គ្រោះកិច្ចសន្យា

- ភាគីមិនបានអនុវត្តករណីកិច្ចផ្តល់តាវកាលិកចម្បងរបស់ខ្លួន



# II វិធីនៃការសង្គ្រោះកិច្ចសន្យា

- ការបំពានកិច្ចសន្យាហួសហេតុ ធ្វើឲ្យបាត់ទំនុកចិត្ត

## ករណីបំពានកិច្ចសន្យាហួសហេតុ



សូមលាបថ្នាំពណ៌ផ្ទះអោយខ្ញុំ
លាបបៃតងខ្ចី ឱ្យហើយក្នុង១ខែ



កិច្ចសន្យាម៉ៅការ

Aជាម្ចាស់ផ្ទះ

Bអ្នកម៉ៅការ



ប៉ុន្តែផ្ទះដែលB បានលាបគឺពណ៌
បៃតងចាស់ ហើយអំឡុងពេល២០
ថ្ងៃបានគន្លងផុត

# II វិធីនៃការសង្គ្រោះកិច្ចសន្យា

- ការរំលាយដែលបានកំណត់ក្នុងកិច្ចសន្យា

កិច្ចសន្យាជួលដី១ឆ្នាំ បានកំណត់ថា បើលោក(ខ) មិន
បានបង់ថ្លៃឈ្នួលដី ២ខែជាប់គ្នា ចាត់ទុកថាឈប់ជួល
ប្រាក់កក់នឹងក្លាយជាប្រយោជន៍របស់លោក (ក)។
ករណីនេះហៅថា ការព្រមព្រៀងជាមុនអំពីលក្ខខណ្ឌ
នៃការរំលាយកិច្ចសន្យាCC#414-1។



ក



ខ



# II វិធីនៃការសង្គ្រោះកិច្ចសន្យា

➢ ការរំលាយដោយការព្រមព្រៀង

លោក (ក) ក៏
យក់ព្រម

ករណីនេះហៅថាការព្រមព្រៀងរំលាយកិច្ចសន្យា CC#414-2.

កិច្ចសន្យាជួលដីរយៈពេល
3 ឆ្នាំ

មួយឆ្នាំក្រោយ លោក
(ខ) ស្នើសុំឈប់ជួល
មុនកំណត់



ក





ខ

# III អានុភាពនៃការរំលាយកិច្ចសន្យា

នៅពេលកិច្ចសន្យាត្រូវបានរំលាយ នាំឱ្យបង្កើតនូវ អានុភាពគតិយុត្ត ណាមួយដូចខាងក្រោម ៖

ទី១ ការរួចផុតពីកាតព្វកិច្ច ឬ

ទី២ កាតព្វកិច្ចបដិទាន ឬ

ទី៣ ការសងការប្រាក់ (CC#411) ។

# III អានុភាពនៃការរំលាយកិច្ចសន្យា

## ក. ការរួចផុតពីកាតព្វកិច្ច

ថ្ងៃទី០៤ ខែ កក្កដា ឆ្នាំ២០១៦បាន
មកដល់ឡានត្រូវចោរលួចបាត់

កិច្ចសន្យាទិញ លក់រថយន្ត
ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៦



Aជាអ្នកទិញ



Bជាអ្នកលក់

ឡានខ្ញុំសូមប្រគល់
អោយនៅ ថ្ងៃទី០៤ ខែ
កក្កដា ឆ្នាំ២០១៦

អញ្ចឹងខ្ញុំនឹង បង់ប្រាក់នៅថ្ងៃ
ប្រគល់ឡាននោះ



# III អានុភាពនៃការរំលាយកិច្ចសន្យា

## ២ ភាគញកិច្ចបដិទាន

ភាគីដែលបានទទួលតាវកាលិកនៃកិច្ចសន្យា តែមួយភាគ ឬទាំងអស់ ត្រូវមានករណីកិច្ចសងតាវកាលិកនោះទៅភាគីម្ខាងទៀត ដើម្បីឱ្យភាគីម្ខាងទៀតទទួលបដិទាន និងប្រសិនបើ ភាគីទាំងសងខាងមានករណីកិច្ចធ្វើបដិទានទៅវិញទៅមក ករណីកិច្ចទាំងនេះត្រូវអនុវត្តនៅពេលជាមួយគ្នា

# III អានុភាពនៃការរំលាយកិច្ចសន្យា

ប្រាក់ថ្លៃឡាននេះ ខ្ញុំសុំនៅខែក្រោយ



បើមិនអោយប្រាក់ថ្លៃឡានមកខ្ញុំ ខ្ញុំសុំរំលាយកិច្ចសន្យា ហើយ សុំប្រគល់ឡានអោយខ្ញុំវិញ



កំណត់ពេលសងបានមកដល់ហើយ តែA នៅតែមិនបង់

កិច្ចសន្យាទិញលក់ឡាន

Aជាអ្នកទិញ

Bជាអ្នកលក់



**ករណីនេះហៅថា កាតព្វកិច្ចបដិទាន**

# III អានុភាពនៃការរំលាយកិច្ចសន្យា

## គ ការសងការប្រាក់

ភាគីដែលមានករណីកិច្ចសងជាការប្រាក់ ដោយការរំលាយត្រូវសងជាមួយនឹងការប្រាក់ដោយគិតចាប់ ពីថ្ងៃដែលបានទទួលប្រាក់ដើម ភាគីដែលមានករណីកិច្ចបង្វិលវត្ថុ ឬតាវកាលិកផ្សេងដែលខ្លួនបានទទួលពីភាគី ម្ខាងទៀតដោយការរំលាយ ត្រូវសងទាំងផលដែលបានទទួលពីវត្ថុ ឬតាវកាលិកនោះ។

# III អានុភាពនៃការរំលាយកច្ចសន្យា

ថ្ងៃទី០៤ ខែ កក្កដា ឆ្នាំ២០១៦បាន
មកដល់ឡានត្រូវចោរលួចបាត់

កិច្ចសន្យាទិញ លក់
ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៦

ឡានខ្ញុំសូមប្រគល់
អោយនៅ ថ្ងៃទី០៤ ខែ
កក្កដា ឆ្នាំ២០១៦





Aជាអ្នកទិញ



Bជាអ្នកលក់



បើគ្មានឡានអោយខ្ញុំទេ សូម
ប្រគល់ប្រាក់ដើម និងការប្រាក់៥%
គិតចាប់ពិថ្ងៃ ខ្ញុំប្រគល់ប្រាក់ដើម។

# ការទាមទារតាមផ្លូវតុលាការ

ប្រសិនបើ ភាគីម្ខាងបានរំលាយកិច្ចសន្យា តាមរយៈការបង្ហាញឆន្ទៈ ហើយអានុភាពនៃការរំលាយកិច្ចសន្យា នាំឲ្យភាគីម្ខាងទៀត ត្រូវប្រគល់តាវកាលិក ជាកាតព្វកិច្ចបដិទាន ប៉ុន្តែ ភាគីនោះមិនបានអនុវត្ត ជាអាទិ៍ អន្តរាគមន៍របស់តុលាការមានភាពចាំបាច់។

ការទាមទារតាមផ្លូវតុលាការ អាចកើតមានឡើង នៅពេលដែលការរំលាយកិច្ចសន្យាបង្កើតអានុភាព ប៉ុន្តែភាគីម្ខាងទៀត មិនអនុវត្តតាមខ្លឹមសារនៃកាតព្វកិច្ចនោះ។

ភាគីមិនអាចស្នើសុំឲ្យតុលាការរំលាយកិច្ចសន្យានោះទេ ខ្លឹមសារនៃការទាមទារនេះគឺគ្មានផលប្រយោជន៍នៃបណ្តឹងនោះទេ។

# សំណួរ-ចម្លើយ




THANK YOU
for your support!